

# សន្លឹកព័ត៌មាន យូ.ភី.អ ឆ្នាំ ២០១៨ ប្រទេសកម្ពុជា ជុំទីបីនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់

## SOGIESC-SRHR

### សិទ្ធិផ្នែកនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) និង សិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ (SRHR) នៅក្នុងប្រទេសកម្ពុជា

ការដាក់ជូនរួមគ្នាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("CCHR") សហគមន៍ឥន្ទធនូកម្ពុជា ("RoCK") អង្គការគោលដៅយុត្តិធម៌ ("DJ") មីក្រូឥន្ទធនូអន្តរជាតិ("MRI") អង្គការថែទាំសុខភាពគ្រួសារកម្ពុជា ("RHAC") សមាគមអន្តរជាតិនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទនៅអាស៊ី ("ILGA-Asia") ក្រុមការងារអាស៊ានស្តីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរនៃយេនឌ័រ និងលក្ខណៈភេទ ("ASC") សមាគមអប់រំផ្លូវភេទស៊ុយអែត ("RFSU") អង្គការអាក់សិនអេតនៅកម្ពុជា (AAC) ជំនួយរបស់វិហារដាណើម៉ាក ("DCA") និង សមាគមអនាគតយុវជនកម្ពុជា-អាស៊ាន (CamASEAN)។

## ខ្លឹមសារសង្ខេបអំពីបញ្ហាសំខាន់ៗនៅក្នុង យូ.ភី.អ ជុំមុន

ក្នុងអំឡុងពេល យូ.ភី.អ លើកទីពីររបស់កម្ពុជាក្នុងឆ្នាំ ២០១៤ ពុំមានអនុសាសន៍ណាមួយត្រូវបានធ្វើឡើងជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ("RGC") ដោយផ្តោតជាចំពោះទាក់ទងជាមួយសិទ្ធិរបស់ប្រជាជនជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និង អ្នកមិនកំណត់ខ្លួនឯងជាក់លាក់ ("អ្នកស្រលាញ់ភេទដូចគ្នា" "LGBTIQ") នោះទេ ហើយមានអនុសាសន៍ពីរធ្វើឡើងដោយប្រទេសអ៊ុយរ៉ូហ្គាយ ដែលផ្តោតជាចំពោះលើ សិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ និងត្រូវបានអនុវត្តមួយផ្នែក។

## ក្របខ័ណ្ឌការងារថ្នាក់ជាតិ

សហគមន៍និងសកម្មជន LGBTIQ កម្ពុជាអាចមានលទ្ធភាពក្នុងការបង្ហាញជាសាធារណៈមួយចំនួន ដោយក្នុងនោះមានព្រឹត្តិការណ៍ LGBTIQ ជាច្រើនត្រូវបានប្រារព្ធឡើង ដោយមានការគាំទ្រខ្លះៗពីសមាជិកនិងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ("RGC")។ ការងារដែលក្រសួងអប់រំយុវជននិងកីឡា ("MoEYS") កំពុងធ្វើនាពេលបច្ចុប្បន្ន ក្នុងការកែសម្រួលកម្មវិធីសិក្សា "បំណិនជីវិត" ឡើងវិញ ដើម្បីដាក់បញ្ចូលសិទ្ធិ SOGIES គឺជាចំណុចគួរជាទីស្ញើចសរសើរជាពិសេស។ ទោះយ៉ាងណាក្តី ច្បាប់និងគោលនយោបាយ ដែលមានលក្ខណៈរើសអើងនៅតែបន្តមាននៅឡើយ ហើយនៅតែមានការអនុវត្តដែលមានលក្ខណៈរើសអើង រួមទាំងការអនុវត្តដោយនគរបាលកម្ពុជាផងដែរ។ ថ្វីបើមានវឌ្ឍនភាពគួរជាទីស្ញើចសរសើរទាក់ទងជាមួយបរិយាប័ន្ន LGBTIQ ក្តី ប៉ុន្តែប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជាបន្តរងការរើសអើងផ្នែកច្បាប់ និងផ្នែកសង្គមក្នុងទម្រង់ផ្សេងៗជាច្រើន ហើយចាំបាច់ត្រូវមានវិធានការគួរជាទីកត់សម្គាល់ពីសំណាក់រដ្ឋាភិបាលកម្ពុជា ដើម្បីធានាឱ្យប្រទេសកម្ពុជាអាចអនុវត្តតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនទាក់ទងជាមួយសិទ្ធិ LGBTIQ។

| បញ្ហាប្រឈម | ផលប៉ះពាល់ |
|---|---|
| **ការរើសអើងផ្នែកច្បាប់ចំពោះ អ្នកស្រលាញ់ភេទដូចគ្នា LGBTIQ** | ប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជាត្រូវជួបប្រទះ**ការរើសអើងក្នុងទម្រង់ជាច្រើន** ដែលបញ្ហានេះបណ្តាលមួយផ្នែកមកពី**ក្របខ័ណ្ឌការងារផ្នែកច្បាប់ដែលបដិសេធសមភាពជាមូលដ្ឋានរបស់ពួកគេ។** សហគមន៍ LGBTIQ កំណត់ឃើញថា មានការរើសអើងផ្នែកច្បាប់ជាអាទិភាពចំនួនបួនទម្រង់គឺ៖<br>(១) **កង្វះការការពារផ្នែកច្បាប់ពីការរើសអើង និងអំពីហឹង្សាមកលើប្រជាជន LGBTIQ**<br>(២) **អវត្តមានការទទួលស្គាល់ផ្នែកច្បាប់លើអត្តសញ្ញាណយេនឌ័រដែលកំណត់ដោយខ្លួនឯង៖** ពុំមានលិខិតបទដ្ឋានគតិយុត្តិណាមួយដែលគាំទ្រសិទ្ធិអ្នកប្តូរយេនឌ័រ ឱ្យត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់យោងតាមយេនឌ័រដែលខ្លួនកំណត់នោះឡើយ ជាហេតុធ្វើឱ្យ**អ្នកប្តូរយេនឌ័រ ក្លាយជាកម្មវត្ថុនៃសេចក្តីសម្រេចចិត្តជាលក្ខណៈបុគ្គលពីសំណាក់មន្ត្រីពាក់ព័ន្ធ។**<br>(៣) **អវត្តមានសមភាពអាពាហ៍ពិពាហ៍នៅក្នុងច្បាប់កម្ពុជា៖** មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា កំណត់ថា**អាពាហ៍ពិពាហ៍គឺធ្វើឡើងរវាង "ប្តី" និង "ប្រពន្ធ"** ដែលជាការផាត់ចេញនូវលទ្ធភាព នៃអាពាហ៍ពិពាហ៍ភេទដូចគ្នា។ ទោះយ៉ាងនេះក្តី **គូស្រករឥន្ទធនូ ៨៧,៨៥% លើកឡើងថា អាពាហ៍ពិពាហ៍មានភាពចាំបាច់ណាស់សម្រាប់ពួកគាត់។**<br>(៤) **ការបដិសេធសិទ្ធិសុំកូនពេញលេញសម្រាប់គូស្រករឥន្ទធនូ ស្របពេលដែលគូស្រករឥន្ទធនូជាច្រើនដែលកំពុងរួមរស់នៅជាមួយគ្នា**ទូទាំងប្រទេសកម្ពុជាដែល**មានកូន**ស្ថិតក្រោមការមើលថែរបស់ខ្លួនរួចហើយ ហើយរបបសុំកូនធម្មតាធ្វើឱ្យពួកគាត់ពុំបានទទួលការការពារផ្នែកច្បាប់ចាំបាច់នានា។ |
| **ការរើសអើងផ្នែកសង្គមចំពោះប្រជាជន LGBTIQ** | ថ្វីបើសហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជាកាន់តែមានភាពលេចធ្លោជាសាធារណៈ ដោយអាស្រ័យមួយផ្នែកដោយសារមានចលនាសិទ្ធិ LGBTIQ កាន់តែធំឡើង និងក្នុងបរិបទដែលពុំសូវមានការប្រឆាំងខ្លាំងក្លាផ្នែកសាសនា ឬផ្នែកស្ថាប័នក្តី ប៉ុន្តែ **ប្រជាជន LGBTIQ កម្ពុជានៅបន្តរងការរើសអើង និងត្រូវបានផាត់ចេញពីវិស័យជាច្រើនក្នុងសង្គម។ ៧៧%** នៃប្រជាជន LGBTIQ និយាយថាពួកគេបានបង្ហាញស្ថានភាពពិតរបស់ខ្លួននៅមានកម្រិត តែចំពោះមិត្តភក្តិជិតស្និទ្ធប៉ុណ្ណោះ ហើយ **៥៤%** បង្ហាញប្រាប់តែសមាជិកគ្រួសារបង្កើតប៉ុណ្ណោះ ដោយសារខ្លាចគេរើសអើង វិនិច្ឆ័យ ធ្វើបាប និងបៀតបៀន នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន។ នៅក្នុងការស្ទាបស្ទង់មតិមួយធ្វើឡើងក្នុងឆ្នាំ ២០១៦ ទៅលើអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីនៅទីប្រជុំជនបានឱ្យដឹងថា អ្នកផ្តល់ចម្លើយចំនួន **៥៣,៤៩%** និយាយថា សមាជិកគ្រួសាររបស់ខ្លួនធ្លាប់បានព្យាយាមបង្ខំពួកគេឱ្យរៀបការនាពេលកន្លងមក ហើយ **៤៨,៨៥%** ធ្លាប់មានអារម្មណ៍ថាពួកគេចាំបាច់ត្រូវចាកចេញពីផ្ទះដោយសារតែ SOGIESC របស់ខ្លួន។ ក្នុងការស្ទាបស្ទង់មតិមួយធ្វើឡើងក្នុងឆ្នាំ ២០១៥ បានបង្ហាញថា**អ្នកផ្តល់ចម្លើយចំនួន ៦២,៧១% ធ្លាប់ជួបបទពិសោធន៍ការធ្វើបាប**នាពេលពួកគេនៅ**សាលារៀន** ហើយ ៩៣,៥៩% នៃអ្នកទាំងនោះមានអារម្មណ៍ថា ការធ្វើបាបនោះអាចបណ្តាលមួយផ្នែក ឬបណ្តាលទាំងស្រុងមកពី SOGIESC របស់ពួកគេ។ ក្នុងការស្ទាបស្ទង់មតិធ្វើឡើងនៅឆ្នាំ ២០១៥ បានបង្ហាញថា អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីចំនួន **៩២%** នៅក្នុងការសិក្សានោះធ្លាប់ជួបបទពិសោធន៍**ការរំលោភបំពានដោយពាក្យសម្តី ៤៣% ជួបអំពើហិង្សាផ្លូវកាយ ៣១% ជួបការធ្វើបាបផ្លូវភេទ និង ២៥% ជួបការរំលោភសេពសន្ថវៈ។** ការសិក្សាដដែលនោះក៏បានបង្ហាញផងដែរថា |



# សន្លឹកព័ត៌មាន យូ.ភី.អរ ឆ្នាំ ២០១៩ ប្រទេសកម្ពុជា
## ជុំទីបីនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់

**SOGIESC-SRHR**

**សិទ្ធិផ្នែកនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ**

**(SOGIESC) និង សិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ (SRHR) នៅក្នុងប្រទេសកម្ពុជា**

| បញ្ហាប្រឈម | ផលប៉ះពាល់ |
|---|---|
| ឱកាសការងារ និងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន អ្នកស្រលាញ់ភេទដូចគ្នា LGBTIQ | ប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជាជួបប្រទះ **ការរើសអើងក្នុងការទទួលបាន និងរក្សាមុខរបរការងាររបស់ខ្លួន** ព្រមទាំង**ការរើសអើង និងការផាត់ចេញនៅកន្លែងធ្វើការ**។ ៣៤,៣៥% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្រ្តីទាំងអស់នៅក្នុងការស្ទាបស្ទង់មតិរបស់ (CCHR) ក្នុងឆ្នាំ២០១៦ បានរាយការណ៍ថាធ្លាប់ត្រូវគេបដិសេធការងារដោយសារតែខ្លួនជាអ្នកប្តូរយេនឌ័រ ហើយ ២៦,៧២% បានរាយការណ៍ថាធ្លាប់រងការបៀតបៀន ឬធ្វើបាបដោយប្រធាន ឬអ្នករួមការងារដោយសារតែ SOGIE របស់ខ្លួន។ ប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជា**ភាគច្រើនធ្វើការនៅក្នុងវិស័យរងការមើលស្រាលមួយចំនួន** ដែលរារាំងពួកគេមិនឱ្យអាចគេចចេញពីវដ្តនៃភាពក្រីក្របាន។ ស្ថានភាពនេះត្រូវបានធ្វើឱ្យធុនដាបកាន់តែខ្លាំងឡើងថែមទៀតដោយសារ**ការបដិសេធពីគ្រួសារ និងការផាត់ចេញ**នៅសាលារៀន និងក្នុងសហគមន៍ទាំងមូល។ ក្នុងចំណោមអ្នកដែលបានរាយការណ៍ថាខ្លួនធ្លាប់ប្រកបរបរសេវាផ្លូវភេទនាពេលមួយក្នុងពេលកន្លងមក **៩៥,៧៤%** ធ្លាប់រងការបៀតបៀនតាមពាក្យសម្តី **៩១,៣%** រងការធ្វើបាបផ្លូវកាយ និង **៨៥,១១%** រងការធ្វើបាបផ្លូវភេទនៅពេលពួកគេប្រកបរបរសេវាផ្លូវភេទ។. |
| ស្ថានភាពរបស់ប្រជាជនអន្តរភេទ | ស្ថានភាពរបស់ប្រជាជនអន្តរភេទ ជាទូទៅនៅពុំទាន់ត្រូវបានសិក្សាស្វែងយល់នៅឡើយទេក្នុងប្រទេសកម្ពុជា។ **នៅមានការខ្វះខាតទាំងស្រុងនូវទិន្នន័យរដ្ឋាភិបាល** និងការស្រាវជ្រាវបោះពុម្ពផ្សព្វផ្សាយស្តីពីប្រជាជនអន្តរភេទ។ |
| សិទ្ធិសុខភាពរបស់ប្រជាជន LGBTIQ | ចំណេះដឹង និងការយល់ដឹងនៅមានកម្រិតស្តីពី SOGIESC ក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈអាជីពសេវាសុខាភិបាលក្នុងប្រទេសកម្ពុជា ហើយការលើកទឹកចិត្ត និងការកសាងសមត្ថភាពលើបញ្ហានេះនៅមានកម្រិតនៅឡើយ រហូតមកទល់សព្វថ្ងៃ។ ២២% នៃ LGBTIQ បានរាយការណ៍ថា ខ្លួនមានអារម្មណ៍ថាអាម៉ាស់ចំពោះសភាពរបស់ខ្លួនឯង។ ជាលទ្ធផលនៅមានដែនកំណត់ជាច្រើនទាក់ទងជាមួយការផ្តល់សេវាសុខភាពដែលមានភាពរួសរាយចំពោះ LGBTIQ ដែលឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ពួកគេ។ ប្រទេសកម្ពុជា បានប្តេជ្ញាចិត្តបញ្ឈប់ជំងឺអេដស៍ត្រឹមឆ្នាំ២០២៥។ សេវាវេជ្ជសាស្ត្រដើម្បីកែតម្រូវយេនឌ័រ គឺនៅពុំមាននៅឡើយ ហើយពុំមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ ឬឯកសាររដ្ឋបាលដែលបញ្ជាក់ថា សេវាទាំងអស់នេះ ជាសេវាស្របច្បាប់ ឬខុសច្បាប់នោះឡើយ។ ជាលទ្ធផល រាល់សេវាប្រភេទនេះដែលមាន គឺពុំមានការគ្រប់គ្រងត្រឹមត្រូវឡើយ។ |
| ការសម្រេចបានការអប់រំអំពីផ្លូវភេទសព្វជ្រុងជ្រោយដែលមានបរិយាប័ន្ន SOGIESC ក្នុងសាលារៀន | ក្នុងឆ្នាំ ២០១៧ ក្រសួងអប់រំយុវជន និងកីឡា ក្រោមការគាំទ្របច្ចេកទេសពីអង្គការសង្គមស៊ីវិល បានអភិវឌ្ឍឱ្យមាន**កម្មវិធីសិក្សា "បំណិនជីវិត" ថ្មីសម្រាប់ថ្នាក់ទី ៥-១២** ស្នើឡើងដើម្បីផ្តល់ការបង្រៀនបែបបរិយាប័ន្នស្តីពីបញ្ហានិន្នាការផ្លូវភេទ ការអប់រំផ្នែកផ្លូវភេទ និងអំពើហិង្សាផ្នែកយេនឌ័រ ហើយគ្រោងដាក់ឱ្យមាននៅទូទាំងប្រទេស ត្រឹមឆ្នាំ២០២៣។ |

## អនុសាសន៍

១. អនុម័តឱ្យមានច្បាប់ប្រឆាំងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា នៅត្រឹមចុងឆ្នាំ ២០២៣ ដែលជួយធានាឱ្យមានសមភាព និងចែងយ៉ាងច្បាស់ការហាមឃាត់ការរើសអើងគ្រប់ប្រភេទ រួមទាំងការរើសអើងដោយឈរលើមូលដ្ឋាន SOGIESC អនុលោមតាម គោលដៅអភិវឌ្ឍដោយចីរភាពទី ៥.១ *[Rec i.]* *

២. អនុម័តឱ្យមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ត្រឹមចុងឆ្នាំ ២០២១។ *[Rec iii.]*

៣. ធ្វើវិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ត្រឹមចុងឆ្នាំ ២០២២។ *[Rec iv.]*

៤. វិសោធនកម្មបទបញ្ញត្តិដែលពាក់ព័ន្ធក្នុងក្រមរដ្ឋប្បវេណី (មាត្រា ១០០៨-១០១៥) ដែលកំណត់លើការសុំកូន ដើម្បីធានាឱ្យមានសិទ្ធិសុំកូនពេញលេញចំពោះគ្រប់គូស្រករទាំងអស់ ត្រឹមចុងឆ្នាំ ២០២១។ *[Rec v.]*

៥. អនុម័តឱ្យមានគោលនយោបាយជាក់លាក់ស្តីពីការមិនរើសអើងដោយឈរលើមូលដ្ឋាន SOGIESC នៅក្នុងសេវាសាធារណៈទាំងអស់របស់រដ្ឋកម្ពុជា ដោយផ្តោតអាទិភាពចំបងនៅក្នុងប្រព័ន្ធអប់រំ (អនុលោមតាម គោលដៅអភិវឌ្ឍដោយចីរភាពទី ៤) វិស័យសុខាភិបាល (អនុលោមតាម គោលដៅអភិវឌ្ឍដោយចីរភាពទី ៣) នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងនៅក្នុងនាយកដ្ឋាននគរបាលនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ (អនុលោមតាម SDG ១៦) ត្រឹមឆ្នាំ ២០២០។ *[Rec vii.]*

៦. ធ្វើវិសោធនកម្មមាត្រា ១២ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិហាមឃាត់ការរើសអើងក្នុងមុខរបរដែលឈរលើមូលដ្ឋាន SOGIESC ត្រឹមឆ្នាំ ២០២១ អនុលោមតាម SDG ៨.៥។ *[Rec x.]*

៧. ធានាឱ្យមានការការពារប្រកបដោយប្រសិទ្ធភាពចំពោះប្រជាជន LGBTIQ ដែលប្រកបរបរសេវាផ្លូវភេទ អនុលោមតាម SDG ៨។ *[Rec xii.]*

៨. ធានាឱ្យបានថា អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកថែទាំសុខភាពទាំងអស់ បានទទួលការបណ្តុះបណ្តាលស្តីពី SOGIESC រួមទាំងតាមរយៈការដាក់បញ្ចូល SOGIESC នៅក្នុងកម្មវិធីសិក្សារបស់សាលាវេជ្ជសាស្ត្រ និងសាលាគិលានុបដ្ឋានឱ្យបានទាន់វដ្ត យូ.ភី.អ ខាងមុខ អនុលោមតាម SDG ៣។ *[Rec xvi.]*

៩. ធានាឱ្យបានថា គ្រូបង្រៀនគ្រប់រូបបានទទួលការបណ្តុះបណ្តាលសព្វជ្រុងជ្រោយស្តីពី SRHR រួមទាំងសិទ្ធិ SOGIESC ត្រឹមចុងឆ្នាំ ២០២២។ *[Rec xx.]*

- *សូមមើលឯកសារដាក់ជូនរួមគ្នាទាំងស្រុងស្តីពីសិទ្ធិ SOGIESC និង SRHR ដើម្បីអានអនុសាសន៍សព្វជ្រុងជ្រោយទាំងស្រុង។ -

For any inquiries, please contact:
rainbowjustice@destinationjustice.org